**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន សាញនីងមូន ឡៃធីង(ខេមបូឌា) ឯ.ក**

កិច្ចព្រមព្រៀង

រវាង

ក្រុមហ៊ុន សាញនីងមូន ឡៃធីង (ខេមបូឌា)ឯ.ក ជាមួយតំណាងកម្មករ និងសហជីព

ប្រចាំក្រុម

ឆ្នាំពីរពាន់ម្ភៃមួយ ខែមេសា ថ្ងៃទី១០ វេលាម៉ោង ៨ និង៣០នាទីព្រឹកនៅការិយាល័យក្រុមហ៊ុន សាញនីងមូន ឡៃធីង (ខេមបូឌា) ឯក មានកិច្ចប្រជុំពិភាក្សា រវាងតំណាងក្រុមហ៊ុន ប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំ សហជីព ទឹកចិត្តកម្មករកម្ពុជា ប្រចាំរោងចក្រ។ ក្រោយពីប្រជុំពិភាក្សា ភាគីទាំងពីរបានយល់ព្រមព្រៀងគ្នា ដូចខាងក្រោម

១-ភាគីទាំងពីរយល់ព្រមព្យួរការងារ រយៈពេល៥០ថ្ងៃ ចំពោះកម្មករនិយោជិកចំនួន៨១នាក់ មានផ្នែកផ្គុំផ្នែក វេចខ្ចប់ ផ្នែកពិនិត្យ ផ្នែកSMT ផ្នែកទូទៅ ផ្នែកឃ្លាំង ផ្នែក ការិយាល័យ ដោយគិតចាប់ពីថ្ងៃទី ១២ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី ៣១ខែឧសភា ឆ្នាំ២០២១ ដោយសារអ្នក ទូរកុងទីនីសំភារៈ ចូលមិនទាន់ពេលកំនត់ ព្រោះប្រទេសទាំងនោះរងផលប៉ះពាល់ពីជម្ងឺ រលាកផ្លូវដង្ហើមធ្ងន់ធ្ងរ ខូវីដ១៩ (COVID19) ។

២-ភាគីកម្មករនិយោជិតយល់ព្រមទទួលប្រាក់ឧបត្ថម ៣០ដុល្លាអាមេរិក ពីភាគីនិយោជក រយៈពេលព្យួរការងារនេះ តាមប្រកាសរបស់ក្រសួង។

៣-ក្រុមហ៊ុននឹងបើកជូនប្រាក់ឧបត្ថម ៣០ដុល្លាអាមេរិកនេះជូនកម្មករនិយោជិត១ខែម្តង។

៤- ក្រុមហ៊ុនសាញនីងមូន ឡៃធីង មានក្តីសោមនស្សរីករាយផ្តល់ជូនបងប្អូនកម្មករនូវប្រាក់អត្ថប្រយោជន៍ដែលមិនត្រូវទទួលបានពីរាជរដ្ឋាភិបាលបន្ថែមទៀត ក្នុង១ខែ៤០ដុល្លា។

៥-បងប្អូនត្រូវត្រលប់ចូលមកធ្វើការវិញ នាថ្ងៃទី ០១មិថុនា ឆ្នាំ ២០២១ ក្នុងករណីបងប្អូន កម្មករមិនបានចូលធ្វើការតាមការកំណត់នេះទេ ក្រុមហ៊ុននឹងអនុវត្តន៍តាមច្បាប់ស្តីពីការងារ និងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន។

កិច្ចព្រមព្រៀងនេះ ចាប់អនុវត្តន៍ និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសៅ ១៣ រោច ខែចេត្រ ឆ្នាំជូត ទោស័ក ពស ២៥៦៤

កំពង់ស្ពឺ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២១

ស្នាមមេដៃតំណាងកម្មករ

១, គិម ចាន់រី

២, អ៊ុំ ឡេទៀង

៣, គីម វណ្ណលីដា

៤, យ៉ាន សុខលីន

តំណាងក្រុមហ៊ុន

ក្រុមហ៊ុន សាញនីងមូន ឡៃធីង (ខេមបូឌា) ឯ.ក
SHININGMOON LIGHTING (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA